រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៦

**សេចក្ដីសំរេចលេខ ២៣ សសរ**

**សេចក្ដីសំរេច**

**ស្ដីពីការប្រគល់ភារកិច្ចបណ្ដោះអាសន្ន**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមការស្នើសុំពីឯកឧត្ដម **អ៊ុង ផន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច

**សំរេច**

**ប្រការ ១** : ប្រគល់ភារកិច្ចជូនឯកឧត្ដម **ណាឌី តាន** អគ្គលេខាធិការនៃរាជរដ្ឋាភិបាល អោយទទួលដឹកនាំ គ្រប់គ្រងការងារអធិការកិច្ច ជំនួសឯកឧត្ដមទេសរដ្ឋមន្ត្រី **អ៊ុង ផន** ចាប់ពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៦ រហូតដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៧ ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង រដ្ឋលេខាធិការអនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្ដម **ណាឌី តាន់** ត្រូវទទួលអនុវត្តសេចក្ដីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ដលេខា និងត្រា | ហត្ថលេខា និង ត្រា |
| **នរោត្ដម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *